ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 30-Oct-2015, 08:25
CMS/CFO: Sann Rada

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

| | |
|---|---|
| **កាលបរិច្ឆេទឯកសារ៖** | **ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៥** |
| **ភាសាដើម៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ** |

---

# សេចក្ដីសម្រេចលើសំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរក្នុងគោលបំណង ដើម្បីវាយតម្លៃលើភាពអាចជឿជាក់បានរបស់ សំ សិទ្ធី

---

**<u>សហព្រះរាជអាជ្ញា</u>**

**<u>សហមេធាវីជនជាប់ចោទ នួន ជា</u>**

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F28/4

ជា លាង
Nicholas KOUMJIAN

**សហព្រះរាជអាជ្ញា**

ខៀវ សំផន
នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

សុន អរុណ
Victor KOPPE

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("**អង្គជំនុំជម្រះតុលាការកំពូល**" និង"**អ.វ.ត.ក**")

**បានទទួល** បាន"សំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍នានាដែលបានពិពណ៌នា នៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សិទ្ធី" ដែលបានដាក់នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ("សំណើសុំ")[1],

**កត់សម្គាល់ឃើញ**ថា នៅក្នុងសំណើនេះ នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល បើកកិច្ចស៊ើបសួរ ក្នុងគោលបំណងវាយតម្លៃលើភាពអាចជឿជាក់បានរបស់សាក្សី សំ សិទ្ធី ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ កាលពីថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ និងបានផ្តល់សក្ខីកម្មដែល នួន ជា បានចាត់ទុកថា "មិនស៊ីសង្វាក់គ្នាចំពោះខ្លឹមសារខាងក្នុង" "ពុំមានភស្តុតាងគាំទ្រ" និង"ពុំគួរឱ្យជឿបាន"[2] និងថា កិច្ចស៊ើបសួរនេះ ដែលរួមមានការធ្វើបទសម្ភាសន៍ជាមួយនឹងបងប្អូនជីដូនមួយរបស់ សំ សិទ្ធី រួមទាំង "អ្នកស្រុក"ដែលពុំបានបញ្ជាក់ច្បាស់លាស់នៅក្នុងស្រុក**ប្រេកស្តេច** ដែលជាទីកន្លែងកប់សាកសព និងទទួលយកអត្ថបទការសែតមួយច្បាប់[3] ត្រូវបានអះអាងថា ជាចំណុចសំខាន់របស់សាក្សីសម្រាប់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង[4] ទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលរងការចោទប្រកាន់ថា បានកាប់សម្លាប់ទាហាន និងអ្នករដ្ឋកាលនៃរបបសាធារណរដ្ឋខ្មែរ[5] និងត្រូវបានស្នើឱ្យធ្វើចំណាត់ការឡើងដោយអ្នកស៊ើបអង្កេតរបស់តុលាការ ឬមេធាវីការពារក្តី នួន ជា[6],

**កត់សម្គាល់ឃើញ**ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា បានជំទាស់ទៅនឹងសំណើសុំនេះ ដោយបានអះអាងថា កិច្ចស៊ើបសួរនេះ គឺជាការអូសបន្លាយពេលវេលានៃ

---

[1] (ជូនដំណឹងនៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥) ឯកសារលេខ F28។

[2] សំណើសុំ កថាខណ្ឌ ២ ដល់ ៣ និង ទំព័រ ១០។

[3] សំណើសុំ កថាខណ្ឌ ៣១។

[4] សាលក្រមនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E313 ("សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង")។

[5] សំណើសុំ កថាខណ្ឌ ២៦ និង ២៨។

[6] សំណើសុំ កថាខណ្ឌ ៣១។

កិច្ចដំណើរការនីតិវិធីដោយពុំចាំបាច់ និងពុំត្រឹមត្រូវ[7] ដោយសារ សំ សិទ្ធី បានរៀបរាប់*ក្នុងចំណោមនោះ* ដំណើររឿងយ៉ាងលម្អិត ស៊ីសង្វាក់គ្នា និងគួរឱ្យជឿជាក់បាន"យ៉ាងខ្លាំង"លើ"ផ្នែកសំខាន់ៗនៃព្រឹត្តិការណ៍ពុំអាចបំភ្លេចបានដែលបានកែប្រែជីវិតរបស់គាត់នៅក្នុងឆ្នាំ ១៩៧៥"[8] ជាដំណើររឿងមួយដែល ពុំតម្រូវឱ្យមានភស្តុតាងគាំទ្រឡើយ[9] និងថា នួន ជា បាននិយាយបំផ្លើសពីទម្ងន់នៃការរ៉ាយរ៉ាប់របស់ សំ សិទ្ធី ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់[10] ដែលតាមទស្សនៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ ពុំបានសម្រេចដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាលជាក់លាក់ដែលបានពិពណ៌នាដោយ សំ សិទ្ធី ឡើយ ប៉ុន្តែ គ្រាត់តែ"បានពិភាក្សា"លើភស្តុតាងរបស់គាត់ និងពុំបានផ្អែកការយល់ឃើញផ្នែកសម្អាងហេតុលើភស្តុតាងនេះទេ ក្រៅតែពី"ការផ្អែកដោយមានកម្រិត" ទាក់ទងទៅនឹងគោលនយោបាយទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកាប់សម្លាប់ទាហាន និងអ្នករដ្ឋកាលនៃរបបសាធារណរដ្ឋខ្មែរ[11],

**កត់សម្គាល់ឃើញ**បន្ថែមទៀតថា សហព្រះរាជអាជ្ញា បានកំណត់ចរឹតលក្ខណៈសំណើនេះថា ទីមួយ ជាការប៉ុនប៉ង"យ៉ាងច្បាស់ក្រឡែត" ក្នុងការអូសបន្លាយពេលវេលានៃកិច្ចដំណើរការនីតិវិធី ដោយបង្ហាញពី "កង្វះខាតនូវការយកចិត្តទុកដាក់ដែលគួរឱ្យភ្ញាក់ផ្អើល" លើពេលវេលា[12] ដែលធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលចំណាយធនធានទៅលើ"កិច្ចការច្រើនលើសលុបជាជាងការផ្តោះទៅរកសាលក្រមស្ថាពរមួយ"[13] និងទីពីរ ទាក់ទងនឹងមធ្យោបាយមួយផ្សេងទៀតរួមជាមួយនឹងសំណើរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម គឺ

---

[7] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍ដែលបានពិពណ៌នាក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សិទ្ធី ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ F28/2 ("សារណាតបរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ ៣ និង២៩។ សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួររបស់ នួន ជា ទាក់ទងទៅនឹង សំ សិទ្ធី ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ F28/1 ("សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី") កថាខណ្ឌ ៤០ ដល់ ៤១។

[8] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧ ដល់ ១៨ និង ២១។

[9] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៥។

[10] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤ និង ២៧។ សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៧។

[11] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៥ ២៨ ដល់ ៣៦។

[12] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣។

[13] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣។

ជាបំពេញបន្ថែមលើសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ដោយបានគេចវេះពីការកំណត់ចំនួនទំព័រ ដែលពាក់ព័ន្ធ[14],

**កត់សម្គាល់ឃើញ**ថា នៅក្នុងការឆ្លើយតប នួន ជា បានអះអាងថា សហព្រះរាជអាជ្ញានិយាយជា "លក្ខណៈទូទៅ" ដោយពុំបានពិនិត្យឱ្យបានជាក់លាក់លើខ្លឹមសារនៃសំណើសុំ និងបានផ្អែកលើយុត្តិសាស្ត្រពុំសមស្រប ហើយព្យាយាមបំផ្លើសការលំបាកនៃដំណោះស្រាយដែលបានស្នើឡើងក្នុងសំណើនោះ[15] រីឯសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានបកស្រាយពុំត្រឹមត្រូវលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែល ពិតប្រាកដណាស់ បានធ្វើឱ្យ នួន ជា ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់ព្រឹត្តិការណ៍ដែលពិពណ៌នាដោយ សំ សិទ្ធី[16]។

**កត់សម្គាល់ឃើញ**បន្ថែមទៀតថា កាលពីការដាក់ឯកសារលើកមុន នួន ជា បានកត់សម្គាល់ថា សហព្រះរាជអាជ្ញា បានលើកមូលហេតុរបស់គាត់ពុំត្រឹមត្រូវ ដោយបាន"ផ្ដល់យោបល់ឥតឈប់ឈរ និងគ្មានភស្តុតាងគាំទ្រ" ថា ទង្វើរបស់គាត់ គឺ"ជាចេតនាអាក្រក់" មានន័យថា សំដៅលើការរំខាន និងអូសបន្លាយពេលវេលានៃកិច្ចដំណើរការនីតិវិធី គេចវេះសាលក្រមស្ពាន[17] ដែលជាការប្រើប្រាស់ភាសាមួយដែលមានលក្ខណៈ"មាក់ងាយខ្លាំង" និង"ធ្វើឱ្យឈឺចាប់ផ្លូវចិត្តខ្លាំង"[18] និងថា នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល"ស្ដីបន្ទោស" សហព្រះរាជអាជ្ញាចំពោះការប្រព្រឹត្តពុំត្រឹមត្រូវបែបនេះ[19],

---

[14] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០។

[15] ការឆ្លើយតបទៅនឹងសារណាតបទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍ ដែលបានពិពណ៌នានៅក្នុងការផ្ដល់សក្ខីកម្មរបស់ សំ សិទ្ធី ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F28/3 ("ការឆ្លើយតបរបស់ នួន ជា") កថាខណ្ឌ ៤, ៨ ដល់ ១០, ១៣, ១៨ ដល់ ២០។

[16] ការឆ្លើយតបរបស់ នួន ជា កថាខណ្ឌ ១៣ ដល់ ១៧។

[17] ការឆ្លើយតបរបស់ នួន ជា ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំមួយសុំពិចារណា និងទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F2/8/6 ("ការឆ្លើយតបរបស់ នួន ជា ពាក់ព័ន្ធនឹងសំណើទីប្រាំមួយ") កថាខណ្ឌ ៦ និង១១។

[18] ការឆ្លើយតបរបស់ នួន ជា ពាក់ព័ន្ធនឹងសំណើទីប្រាំមួយ កថាខណ្ឌ ៧។

[19] ការឆ្លើយតបរបស់ នួន ជា ពាក់ព័ន្ធនឹងសំណើទីប្រាំមួយ កថាខណ្ឌ ១១។

**ពិចារណាឃើញ**ថា នួន ជា នៅពេលនោះ បានប្រើប្រាស់សំណើសុំ និងពាក្យសុំផ្សេងៗ ដើម្បីបំពេញបន្ថែមលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ខ្លួន[20] ដោយបានគេចវេះយ៉ាងមានប្រសិទ្ធិភាពជាពិសេសពីការកំណត់កាលបរិច្ឆេទ និងចំនួនទំព័រដែលបានកម្រិតដោយអង្គជំនុំជម្រះតុលាការកំពូល[21] ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ សារណាទាំងនោះ ភាគច្រើនជាប់ពាក់ព័ន្ធទៅនឹងការលើកឡើងពីគោលបំណងត្រឹមត្រូវតាមច្បាប់ក្នុងសំណើសុំនោះ និងថា គ្រប់ពេលទាំងអស់ សហព្រះរាជអាជ្ញា បានប្រើប្រាស់ជាប្រចាំនូវលទ្ធភាពនីតិវិធីដែលខ្លួនមាន ក្នុងការឆ្លើយតប រួមទាំងសំណើសុំបន្ថែមទំព័រ[22] ក្នុងដើម្បីសម្រាលក្តីបារម្ភរបស់ខ្លួនអំពីបញ្ហាដែលថា គោលការណ៍ស្តីពីតុល្យភាពតទល់ អាចនឹង“គ្មានតុល្យភាពទាំងស្រុង”[23],

**ពិចារណាឃើញ**ថា ផ្ទុយទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញា[24] នួន ជា កន្លងមក បានប្រើប្រាស់សិទ្ធិក្នុងការបង្ហាញភស្តុតាងក្នុងការការពារខ្លួនក្នុងលក្ខណៈមួយយ៉ាងធំទូលាយ ប៉ុន្តែត្រឹមត្រូវតាមច្បាប់ នៅក្នុងកិច្ចដំណើរការនីតិវិធី និងថា ដោយសារពុំមានការអះអាងណាមួយដែលថា នួន ជា បានដាក់សំណើ

---

[20] *សូមមើល* សំណើសុំ កថាខណ្ឌ ៤ ដល់ ២៨។ សំណើទីប្រាំមួយរបស់ នួន ជា សុំពិចារណា និងទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ F2/8 កថាខណ្ឌ ៩ ដល់ ១៣ និង ១៨ ដល់ ៦៩។

[21] សេចក្តីសម្រេចស្តីពីសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួន ទំព័រលើបណ្តឹងសាទុក្ខ និងពេលវេលាក្នុងការឆ្លើយតប ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ F13/2។ សេចក្តីសម្រេចស្តីពីសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រលើសារណាបណ្តឹងសាទុក្ខ និងសារណាតប ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ F9។

[22] សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រ និងដាក់តែមួយភាសា ជាការឆ្លើយតបទៅនឹងសំណើសុំដាក់ភស្តុតាងបន្ថែមលើកទីប្រាំមួយរបស់ នួន ជា ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ F2/8/2។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រសម្រាប់ដាក់សារណាតបទៅនឹងសំណើសុំដាក់ភស្តុតាងបន្ថែមលើកទីប្រាំមួយរបស់ នួន ជា ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F2/8/2/1។

[23] សារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើទីប្រាំមួយរបស់ នួន ជា សុំពិចារណា និងទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F2/8/5 (“សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំមយយ”) កថាខណ្ឌ ៣៥។

[24] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំមួយ កថាខណ្ឌ ៤ , ៧ និង ៤១។

យឺតពេល ឬឥតបានការ ទើបធ្វើឱ្យសំណើជាច្រើនរបស់ នួន ជា ពុំត្រូវបានអង្គជំនុំជម្រះនេះ ទទួលយកកន្លងមកនោះទេ[25],

**ពិចារណាឃើញ**បន្ថែមទៀតថា សហព្រះរាជអាជ្ញា នៅក្នុងសារណាតបរបស់ខ្លួនទៅនឹងសំណើបច្ចុប្បន្ននេះ និងសំណើទីប្រាំមួយ បានប្រើប្រាស់ភាសា ដែលគេអាចដឹងបានថា ជាការមាក់ងាយទៅលើមេធាវីការពារក្តី នួន ជា ឬការពោលបញ្ឆិតបញ្ឆៀង[26] ដែលអង្គជំនុំជម្រះរំពឹងថា នឹងគួរជៀសវាងនៅក្នុងសារណាក្រោយៗ ប៉ុន្តែថា ការប្រើប្រាស់ភាសានេះ ពុំមានលក្ខណៈគ្រប់គ្រាន់ឈានដល់កម្រិតធ្ងន់ធ្ងរ ឬអាចបង្កើតបានជាលំនាំនៃការប្រព្រឹត្តដោយស៊ីសង្វាក់គ្នាមួយ ដែលអាចតម្រូវឱ្យមានការស្តីបន្ទោសជាផ្លូវការឡើយ,

**ពិចារណាឃើញ**ថា ផ្នែកជាច្រើននៃការតវ៉ាដែលបានលើកឡើងក្នុងសំណើនេះ គឺបង្ហាញពីភាពគួរជឿជាក់បានរបស់សាក្សី សំ សិទ្ធី និងសារៈសំខាន់នៃសក្ខីកម្មរបស់គាត់ទៅនឹងការយល់ឃើញមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូង និងថា កន្លែងដែលសមស្របបំផុតសម្រាប់ដោះស្រាយទឡ្ហីករណ៍ទាំងនេះ គឺនៅក្នុងសាលដីកាបណ្តឹងសាទុក្ខខាងមុខក្នុងសំណុំរឿង ០០២/០១,

**ពិចារណាឃើញ**ថា សាក្សី បានផ្តល់សក្ខីកម្មនៅក្នុងតុលាការជាសាធារណៈ ហើយផ្អែកលើមូលដ្ឋាននេះ និងក្នុងបរិបទនៃសម្ភារៈទាំងមូល អាចឱ្យអង្គជំនុំជម្រះរកឃើញពីភាពអាចជឿជាក់បាន ដោយពុំចាំបាច់បើកកិច្ចស៊ើបសួរបន្ថែម ដោយហេតុថា សក្ខីកម្មរបស់សាក្សី វិសាលភាពនៃភាពស៊ីសង្វាក់គ្នា និងអត្តចរិតក្នុងចំណោមកត្តាផ្សេងៗទៀត គឺជាការបង្ហាញគ្រប់គ្រាន់ទៅតាមតម្រូវការក្នុងការវាយតម្លៃ,

**ពិចារណាឃើញ**ថា ដើម្បីវាយតម្លៃលើភាពអាចជឿជាក់បាន និងទុកចិត្តបានរបស់ សំ សិទ្ធី ក៏ដូចជាភាពជាប់ពាក់ព័ន្ធនៃចម្លើយរបស់គាត់ ធៀបទៅនឹងការយល់ឃើញមួយចំនួនរបស់តុលាការជាន់ដំបូងដែល

---

[25] សម្រាប់ប្រវត្តិនីតិវិធី *សូមមើល* សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ និងបញ្ហាពាក់ព័ន្ធ-ផ្នែកសម្រេចសេចក្តី-ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F2/9។

[26] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំមួយ កថាខណ្ឌ ១៩ ("ការអះអាងមានលក្ខណៈរវើរវាយ") កថាខណ្ឌ ៣២ ("និយាយដដែលៗយ៉ាងវក់វីដូចគោទំពាអៀង") កថាខណ្ឌ ៣៥ ("ការប៉ុនប៉ងកំណត់អត្តសញ្ញាណដោយបន្តុះបង្អាប់នូវភស្តុតាងដែលមានឥទ្ធិពលអាក្រក់នៅលើបណ្តឹងសាទុក្ខ ដោយបន្តធ្វើជាសំណើសុំបើកកិច្ចស៊ើបសួរ") កថាខណ្ឌ ៦៨ ("ការប៉ុនប៉ងក្នុងការនិយាបញ្ឆិតបញ្ឆៀងអំពីផែនការក្បត់របស់'ភូមិភាគពាយ័ព្យ' នួន ជា") និង កថាខណ្ឌ ៤, ៧, ១៤, ៦១ និង សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣ (ការកំណត់ដដែលនូវគោលបំណងសំខាន់(ឬតែមួយ)នៃសំណើសុំរបស់ នួន ជា ថាជាការអូសបន្លាយពេលវេលា និងរំខានដល់កិច្ចដំណើរការនីតិវិធី ដើម្បី"អូសបន្លាយការចេញសាលដីកាលើបណ្តឹងសាទុក្ខ […] ឱ្យបានយូរតាមដែលអាចធ្វើទៅបាន")។

មានភាពចម្រូងចម្រាសនោះ នៅក្នុងកាលៈទេសៈបច្ចុប្បន្ន ពុំមានលក្ខណៈចាំបាច់ដែលតម្រូវឱ្យបើកកិច្ចស៊ើបសួរបន្ថែម ពីព្រោះអង្គជំនុំជម្រះនេះ បានធ្វើសេចក្តីសន្និដ្ឋានរួចរាល់ហើយទៅលើចំណុចដែលខ្លួនយល់ថា ចាំបាច់ក្នុងការវាយតម្លៃពីសក្ខីកម្មផ្ទាល់របស់សាក្សីរូបនេះ,

## អាស្រ័យហេតុនេះសម្រេច÷

**បដិសេធ**សំណើនេះចោល។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រឹម**